ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៣០/១២-ខេមបូ ហ៊ែនសាំ (សាខាទី១)
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ រុន សារ៉ាយ

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ ក្រុមហ៊ុន **ខេមបូ ហ៊ែនសាំ អិលធីឌី (សាខាទី១)**
អាសយដ្ឋាន ៖ ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ២៤៩ ៦៣៣ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ ៖

១- លោក Do Sang Kyu ប្រធានផ្នែកច្បាប់
២- លោក ចាន់ ដារ៉ុច ប្រធានផ្នែករដ្ឋបាល
៣- លោក ប៉ុន បូរិត បុគ្គលិកផ្នែកច្បាប់

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២ ៖

១- លោក Do Sang Kyu ប្រធានផ្នែកច្បាប់
២- លោក ចាន់ ដារ៉ុច ប្រធានផ្នែករដ្ឋបាល
៣- លោក ប៉ុន បូរិត បុគ្គលិកផ្នែកច្បាប់



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh+ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org+ Website: www.arbitrationcouncil.org

៤- លោក ហំ ភា មេធាវី

២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖- **សហព័ន្ធសហជីពមិត្តភាពកម្មករ**

- **សហជីពមិត្តភាពកម្មករក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី, ១**

អាសយដ្ឋាន ៖ ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៨ ៨៩ ៩៩ ៥៥៩ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ ៖

| | |
|---|---|
| ១- លោក សុខ គ្រុយ | មេធាវី |
| ២- លោក សៀង សម្បត្តិ | ប្រធានសហព័ន្ធសហជីពមិត្តភាពកម្មករ |
| ៣- លោក វ៉ាន់ វីន | ប្រធានសហជីពមិត្តភាពកម្មករប្រចាំក្រុមហ៊ុន |
| ៤- លោក យី ដាវី | អនុប្រធានសហជីពមិត្តភាពកម្មករប្រចាំក្រុមហ៊ុន |
| ៥- លោក យី ដាវុធ | ប្រធានសហជីពពលកម្មកម្ពុជាប្រចាំក្រុមហ៊ុន |
| ៦- លោក អ៊ុន ដារ៉ា | អនុប្រធាន CNCLP |
| ៧- លោក លី ថាវី | មន្ត្រី CNCLP |

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី២ ៖

| | |
|---|---|
| ១- លោក សុខ គ្រុយ | មេធាវី |
| ២- លោក សៀង សម្បត្តិ | ប្រធានសហព័ន្ធសហជីពមិត្តភាពកម្មករ |
| ៣- លោក យី ដាវី | អនុប្រធានសហជីពមិត្តភាពកម្មករប្រចាំក្រុមហ៊ុន |
| ៤- លោក យី ដាវុធ | ប្រធានសហជីពពលកម្មកម្ពុជាប្រចាំក្រុមហ៊ុន |
| ៥- លោក អ៊ុន ដារ៉ា | អនុប្រធាន CNCLP |
| ៦- លោក លី ថាវី | មន្ត្រី CNCLP |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពមិត្តភាពកម្មករប្រចាំរោងចក្រ លោក វ៉ាន់ វីន លោក យី ដាវី និងលោក យី ដាវុធ ឱ្យចូលធ្វើការវិញ ហើយត្រូវបើកប្រាក់រំលឹកជូនពួកគាត់ ។

២- ក្រុមហ៊ុនត្រូវដកពាក្យបណ្តឹងពីតុលាការដែលក្រុមហ៊ុនបានប្តឹងប្រធានសហជីពលោក វ៉ាន់ វីន ដោយគ្មានកំហុស និងដកពាក្យបណ្តឹង ដែលបានប្តឹងលោក យី ដាវី និងលោក យី ដាវុធ ឱ្យសងចំនួន ១៦៣០០ ដុល្លារអាមេរិក ។

៣- សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់ជំនាញជូនកម្មករចេះម៉ាស៊ីនមួយចំនួន ៣ ដុល្លារ ចេះម៉ាស៊ីនពីរចំនួន ៦ដុល្លារ និងចេះម៉ាស៊ីនបីចំនួន ១០ ដុល្លារក្នុងមួយខែ ។

៤- សូមឱ្យក្រុមហ៊ុនបន្ថែមប្រាក់ឈ្នួលចំនួន ៥ ដុល្លារចំពោះកម្មករណា ដែលធ្វើការងារលើសពីពីរឆ្នាំ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៦៥ កប/អក/វក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖**

- លើកទី១ ៖ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២ (វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក ) ។
- លើកទី២ ៖ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១២ (វេលាម៉ោង ២ រសៀល ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពមិត្តភាពកម្មករលេខ ០៣/១២ សមក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១២ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញចុះធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៤ ចំណុច លើការទាមទារចំនួន ០៤ ចំណុច។ ចំណុចមិនសះជាចំនួន០៤ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ១៦៥ កប/អក /វក/ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២ ។

THE ARBITRATION COUNCIL

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៤ ចំណុចនេះ លើកទី១នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ នាវេលាម៉ោង ៨ និង ៣០នាទីព្រឹក និងលើកទី២ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១២។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន០៤ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាទេ។

នៅក្នុងសំណុំរឿងនេះ ភាគីវិវាទទាំងពីរជ្រើសរើសយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ច។

សេចក្តីបង្គាប់អាជ្ញាកណ្តាលត្រូវចេញនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១២ ប៉ុន្តែភាគីទាំងពីរបានឯកភាពពន្យាថ្ងៃចេញសេចក្តីបង្គាប់ទៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណានិងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាងនិងការរកឃើញនៃអង្គហេតុដូចខាងក្រោម ៖

**ភស្តុតាង ៖**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន ៖**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់នាយកក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ជូនលោកមេធាវី ហ៊ំ ភា ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ ។

២- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ជូនលោក Do Sang Kyu ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១២ ។

៣- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ជូនលោក Do Sang Kyu ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ ។

៤- ដីការកោះរបស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ សំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៩៩ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២។

៥- ពាក្យការពារក្តីរបស់មេធាវី ហ៊ំ ភា គោរពជូនលោកព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ លេខ ០៧៩ កហភ/១១ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការតំណាង និងការការពារក្តីឱ្យក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ១ ក្នុងសំណុំ រឿងព្រហ្មទណ្ឌលេខ ៣៧៩៩ ចុះថ្ងៃទី១៥-១២-២០១១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

៦- ពាក្យស្នើសុំរបស់នាយកក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ គោរពជូនប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការ

ស្នើសុំឱ្យសម្រេចលើការស្នើសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីពមិត្តភាពកម្មករចំនួន ២ នាក់ និងសហជីពពលកម្មកម្ពុជា ១ នាក់ ដែលមានឈ្មោះ វ៉ាន់ វីន ឈ្មោះ យី ដាវី និងឈ្មោះ យី ដាវុធ ពីបទបានប្រព្រឹត្តកំហុសធ្ងន់ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១២ ។

៧- លិខិតរបស់នាយក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការស្នើសុំបញ្ឈប់ការងារលោក វ៉ាន់ វីន អត្តលេខ ៥-១០៦៥ ជាកម្មករផ្នែកអ៊ុត និងជាប្រធានសហជីពមិត្តភាពកម្មករ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។

៨- លិខិតរបស់នាយក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការស្នើសុំបញ្ឈប់ឈ្មោះ យី ដាវី អត្តលេខ ៤៨៥៨ ជាធ្វើការនៅផ្នែកជាងម៉ាស៊ីន និងជាអនុប្រធានសហជីពមិត្តភាពកម្មករ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។

៩- លិខិតរបស់នាយក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ គោរពជូនលោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីការស្នើសុំបញ្ឈប់ឈ្មោះ យី ដាវុធ អត្តលេខ ៦២១១ ជាធ្វើការនៅផ្នែកជាងម៉ាស៊ីន និងជាប្រធានសហជីពពលកម្មកម្ពុជា ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។

១០- កំណត់ហេតុអនុវត្ត ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១ ។

១១- ដីការសំរេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ លេខ ១៦ "ជ" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ។

១២- លិខិតរបស់នាយកដ្ឋានវិវាទការងារលេខ ០៣២ កប/អក/វក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ជម្រាបមកលោកនាយកក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ស្តីពីការស្នើសុំបញ្ឈប់ការងារថ្នាក់ដឹកនាំសហជីពមិត្តភាពកម្មករចំនួន ០២ នាក់ និងសហជីពពលកម្មកម្ពុជាចំនួន ០១ នាក់ ដែលមានឈ្មោះ វ៉ាន់ វីន យី ដាវី និង យី ដាវុធ ពីបទបានប្រព្រឹត្តកំហុសធ្ងន់ ។

១៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៧ ។

១៤- លក្ខន្តិកៈក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៨ ។

១៥- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ ។

១៦- សេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៦២/១១-ខេមបូហ៊ែនសាំ (សាខាទី១) ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ។

១៧- ពាក្យស្នើសុំផ្តល់ឯកសាររបស់ការិយាល័យមេធាវី ហំ ភា លេខ ០២៧ កហក/១២ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១២ ពាក់ព័ន្ធក្នុងសំណុំរឿងលេខ ៣០/១២ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

១៨- សារណាវិវាទការងាររួមរបស់សំណុំរឿងលេខ ៣០/១២ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០២៦ កហក/១២ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១២ ។/

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់លោក សៀង សម្បត្តិ ជូនលោកមេធាវី សុខ គ្រុយ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ ។

២- លិខិតស្នើសុំអន្តរាគមន៍របស់កម្មករ កម្មការិនីនៃក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ សូមគោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីសំណើសុំជួយអន្តរាគមន៍ចំពោះរោងចក្រ ខេមបូ ហ៊ែនសាំ ១ ឱ្យដកពាក្យបណ្តឹង ដែលក្រុមហ៊ុនបានប្រើល្បិចប្តឹងថ្នាក់ដឹកនាំសហជីពទៅតុលាការ និងព្យួរកិច្ចសន្យាថ្នាក់ដឹកនាំសហជីពចំនួន ០៣ រូប ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៣- សេចក្តីថ្លែងការណ៍រួមរបស់សហភាពជាតិកម្ពុជាការពារកម្មករមានចំនួន ៨ សហព័ន្ធ, សម្ព័ន្ធសហព័ន្ធសហជីពជាតិកម្ពុជាមានចំនួន ៦ សហព័ន្ធ, សហភាពពលកម្មកម្ពុជាមានចំនួន ៥ សហព័ន្ធ និងសហព័ន្ធសហជីពឯករាជ្យចំនួន ៦ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៤- លិខិតស្នើសុំអន្តរាគមន៍របស់សហភាពជាតិកម្ពុជាការពារកម្មករមានចំនួន ៨ សហព័ន្ធ, សម្ព័ន្ធសហព័ន្ធសហជីពជាតិកម្ពុជាមានចំនួន ៦ សហព័ន្ធ, សហភាពពលកម្មកម្ពុជាមានចំនួន ៥ សហព័ន្ធ និងសហព័ន្ធសហជីពឯករាជ្យមួយចំនួន សូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រី អ៊ិត សំហេង ប្រធានគណៈកម្មការដោះស្រាយកូដកម្ម-បាតុកម្ម គ្រប់មុខសញ្ញា ស្តីពីសំណើសុំជួយអន្តរាគមន៍ចំពោះរោងចក្រ ខេមបូ ហ៊ែនសាំ ១ ដែលបានប្តឹងថ្នាក់ដឹកនាំសហជីពទៅតុលាការ និងព្យួរកិច្ចសន្យាថ្នាក់ដឹកនាំសហជីពចំនួន ០៣ រូប ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ ។

៥- លិខិតរបស់នាយកដ្ឋានវិវាទការងារលេខ ៦៤៣ កប/អក/វក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ជំរាបមកលោកប្រធានសហជីពមិត្តភាពកម្មករក្រុមហ៊ុន ខេមបូ ហ៊ែនសាំ១ ស្តីពីការសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី ។

៦- លិខិតបញ្ជាក់ពីភាពពេញលក្ខណៈច្បាប់របស់សហជីពមិត្តភាពកម្មករក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ លេខ ១៨០ កប ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១០ ។

៧- លិខិតបញ្ជាក់ពីភាពពេញលក្ខណៈច្បាប់របស់សហជីពពលកម្មកម្ពុជា ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ លេខ ១៩៩ កប ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១ ។

៨- លិខិតរបស់នាយកដ្ឋានវិវាទការងារលេខ ០៣២ កប/អក/វក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ជម្រាបមកលោកនាយកក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ស្តីពីការស្នើសុំបញ្ឈប់ការងារថ្នាក់ដឹកនាំសហជីពមិត្តភាពកម្មករចំនួន ០២ នាក់ និងសហជីពពលកម្មកម្ពុជាចំនួន ០១ នាក់ដែលមានឈ្មោះ វ៉ាន់ រិទ្ធី យី ដាវី និង យី ដារ៉ុធ ពីបទបានប្រព្រឹត្តកំហុសធ្ងន់ ។

៩- សារណាសង្ខេប ស្តីពីដំណើរការក្នុងរឿងវិវាទការងារដែលកើតមានឡើងក្នុងក្រុមហ៊ុន ខេមបូ ហ៊ែនសាំ ១ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ១ លេខ ១៦៥ កប/អក/វក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ១ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី១ លេខ ១៧៣ កប/អក/វក/លកអ. ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ លេខ ១៧៤ កប/អក/វក/លកអ. ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ២៣៩ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ២៤០ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២។

៥- កិច្ចព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ច ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ ក្នុងសំណុំរឿងលេខ ៣០/១២ ។

**អន្តរហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា៖

- ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ១ មានជួលកម្មករនិយោជិតសរុបចំនួន ១៨០០ នាក់។
- សហជីពមិត្តភាពកម្មករជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។ សហជីពនេះ មានសមាជិកប្រហែលជា ៨៤០ នាក់ ប៉ុន្តែមិនមានភាពជាតំណាងបំផុតនៅក្នុងក្រុមហ៊ុនទេ។

THE ARBITRATION COUNCIL

ចំណុចវិវាទទី១ ៖ សូមឱ្យនិយោជកទទួលយកថ្នាក់ដឹកនាំសហជីពមិត្តភាពកម្មករប្រចាំរោងចក្រលោក វ៉ាន់ វីន លោក យី ដាវី និងលោក យី ដាវុធ ឱ្យចូលធ្វើការវិញ ហើយត្រូវបើកប្រាក់រំលឹកជូនពួកគាត់

- និយោជកបានចោទប្រកាន់លោក វ៉ាន់ វីន ប្រធានសហជីពមិត្តភាពកម្មករថា បានលួចអាវរបស់ក្រុមហ៊ុនដាក់ក្នុងកែបម៉ូតូរបស់គាត់ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។ និយោជកបានសម្រេចព្យួរកិច្ចសន្យាការងាររបស់កម្មកររូបនេះ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ តែម្តង។
- និយោជកបានចោទប្រកាន់លោក យី ដាវី អនុប្រធានសហជីពមិត្តភាពកម្មករ និងលោក យី ដាវុធ ប្រធានសហជីពពលកម្មកម្ពុជាថា បានដើររំខាន និងញុះញង់ដល់កម្មករក្នុងម៉ោងធ្វើការឱ្យធ្វើកូដកម្ម កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។ និយោជកក៏បានសម្រេចព្យួរកិច្ចសន្យាការងាររបស់កម្មករទាំងពីររូបនេះ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។
- នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ លោកមេធាវី ហំ ភា ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ LEE WOON HUN ជានាយកគ្រប់គ្រងក្រុមហ៊ុន ខេមបូ ហ៊ៃនសាំ អិលធីឌី ១ បានដាក់ពាក្យសុំចេញដីកាសម្រេចរក្សាការពារ។
- សាលដំបូងរាជធានីភ្នំពេញបានចេញដីកាសម្រេចរក្សាការពារលេខ ១៦ "ជ"ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលមានសេចក្តីសម្រេចត្រង់ចំណុចទី១ ដូចតទៅ " *បង្គាប់ឱ្យកម្មករនិយោជិតដែលកំពុងចូលរួមធ្វើកូដកម្មនៅមុខរោងចក្រ ខេមបូ ហ៊ៃនសាំ អិលធីឌី ១ ដែលមានទីតាំងស្ថិតនៅភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោរាជធានីភ្នំពេញ ឱ្យចូលធ្វើការងារតាមកន្លែងដើមវិញក្នុងរយៈពេល៤៨ម៉ោង ដោយអនុវត្តឱ្យបានត្រឹមត្រូវតាមមាត្រា ៣៣៧ នៃច្បាប់ស្តីពីការងារជាបណ្តោះអាសន្ន លើកលែងតែឈ្មោះដែលត្រូវបានក្រុមហ៊ុនព្យួរការងារតាមនីតិវិធីច្បាប់ស្តីពីការងារ រងចាំរហូតដល់រឿងអង្គសេចក្តីត្រូវបានតុលាការដោះស្រាយចប់ជាស្ថាពរ* "។
- និយោជកបានស្នើសុំបញ្ឈប់កម្មករនិយោជិតទាំងបីរូបនេះ ទៅនាយកដ្ឋានវិវាទការងារតាមរយៈលិខិតស្នើសុំថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។
- ដីកាកោះ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ អញ្ជើញឈ្មោះ LEE WOON HUN ជាដើមបណ្តឹង ឱ្យចូលទៅកាន់អយ្យការ អមសាលាដំបូងរាធានីភ្នំពេញ ដើម្បីសាកសួរពីដំណើររឿងប្តឹងឈ្មោះ វ៉ាន់ វីន ពីបទលួចអាវរោងចក្រ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៩៩ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១។
- នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០១២ និយោជកបានដាក់លិខិតទៅនាយកដ្ឋានវិវាទការងារ ក្នុងកម្មវត្ថុស្នើសុំឱ្យសម្រេចលើការស្នើសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីពមិត្តភាពកម្មករចំនួន ២ នាក់ និងសហជីពពលករកម្ពុជាចំនួន ១ នាក់ ដែលមានឈ្មោះ វ៉ាន់ វីន ឈ្មោះ យី ដាវី និងឈ្មោះ យី ដាវុធ ពីបទប្រព្រឹត្តកំហុសធ្ងន់។
- នាយកដ្ឋានវិវាទការងារបានចេញលិខិតលេខ ០៣២ កប/អក/វក.ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ផ្ញើជូននាយកក្រុមហ៊ុន ខេមបូ ហ៊ៃនសាំ អិលធីឌី ១ ជាការឆ្លើយតបទៅនឹងការស្នើសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីព

THE ARBITRATION COUNCIL

ទាំង៣រូបខាងលើ ។ លិខិតនេះ សរសេរថា “*ដោយសារសំណុំរឿងខាងលើកំពុងស្ថិតនៅក្នុងសមត្ថកិច្ចរបស់សាលាដំបូងរាជធានីភ្នំពេញ នោះនាយកដ្ឋានវិវាទការងារពុំមានសមត្ថកិច្ចដោះស្រាយលើសំណុំរឿងនេះបានឡើយ*” ។

- ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកយកកម្មករនិយោជិតទាំង ៣ នាក់ចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួលតាំងពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ ។
- ភាគីនិយោជកមិនឯកភាពនឹងការទាមទារនេះទេ ដោយលើកឡើងថា រងចាំការសម្រេចអង្គសេចក្តីរបស់តុលាការ ។

ចំណុចវិវាទទី២ ៖ និយោជកត្រូវដកពាក្យបណ្តឹងពីតុលាការ ដែលនិយោជកបានប្តឹងប្រធានសហជីពលោក វ៉ាន់ វីន ដោយគ្មានកំហុស និងដកពាក្យបណ្តឹងដែលបានប្តឹងលោក យី ដាវី និងលោក យី ដាវុធ ឱ្យសងចំនួន ១៦៣០០ដុល្លារអាមេរិក

- ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកដកពាក្យបណ្តឹងអាជ្ញា ចោទប្រកាន់លោក វ៉ាន់ វីន និងពាក្យបណ្តឹងរដ្ឋប្បវេណីទាមទារសំណងខូចខាតចំនួន ១៦ ៣០០ ដុល្លារអាមេរិក ពីលោក យី ដាវី និងលោក យី ដាវុធ ។
- ភាគីនិយោជកមិនឯកភាពនឹងការទាមទារនេះទេ ។

ចំណុចវិវាទទី៣ ៖ សូមឱ្យនិយោជកផ្តល់ប្រាក់ជំនាញជូនកម្មករចេះម៉ាស៊ីនមួយចំនួន៣ដុល្លារ ចេះម៉ាស៊ីនពីរចំនួន ៦ ដុល្លារ និងចេះម៉ាស៊ីន៣ ចំនួន ១០ ដុល្លារក្នុងមួយខែ

- ភាគីនិយោជកមិនឯកភាពនឹងការទាមទារនេះទេ ដោយយោងថា សហជីពមិត្តភាពកម្មករមិនមានភាពជាតំណាងបំផុតទេ ដូចនេះមិនអាចចរចាលើការទាមទារនេះទេ ។
- ភាគីនិយោជកបានលើកឡើងថា ការអនុវត្តនៅក្នុងក្រុមហ៊ុន អ្នកគ្រប់គ្រងទូទៅធ្វើការសម្រេចចិត្តដោយផ្អែកទៅលើរបាយការណ៍សម្ភាសន៍ការងារ ដែលផ្នែករដ្ឋបាលសម្ភាសន៍កម្មករនិយោជិត នៅពេលជ្រើសរើសឱ្យចូលបំរើការងារ និងការវិនិច្ឆ័យជាក់ស្តែងដែលប្រធានក្រុមចិនផ្តល់ឱ្យ ។

ចំណុចវិវាទទី៤៖ សូមឱ្យនិយោជកបន្ថែមប្រាក់ឈ្នួលចំនួន ៥ដុល្លារ ចំពោះកម្មករណាដែលធ្វើការងារលើសពីពីរឆ្នាំ

- ភាគីកម្មករនិយោជិតធ្វើការទាមទារនេះ ដោយយោងលើមូលហេតុថា ជីវភាពកម្មករមានការលំបាកព្រោះការហូបចុកមិនគ្រប់គ្រាន់ ដែលបណ្តាលមកពីប្រាក់ឈ្នួលទាប ។ ជាលទ្ធផល កម្មករនិយោជិតមានសុខភាពទន់ខ្សោយ ។
- ភាគីនិយោជកមិនឯកភាពនឹងការទាមទារនេះទេ ។

THE ARBITRATION COUNCIL

**ហេតុផលនៃសេចក្តីសម្រេច ៖**

ចំណុចវិវាទទី១៖ កម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកថ្នាក់ដឹកនាំសហជីពមិត្តភាពកម្មករប្រចាំរោងចក្រ លោក វ៉ាន់ រីន លោក យី ដារី និងលោក យី ដាវុធ ឱ្យចូលធ្វើការវិញ និងទាមទារឱ្យបើកប្រាក់រំលឹកជូនពួកគាត់

សហជីពមិត្តភាពកម្មករបានធ្វើការទាមទារចំណុចវិវាទដូចគ្នានេះ ចំពោះក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ១ នៅក្នុងសំណុំរឿងលេខ ១៦២/១១ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១១។

ផ្អែកតាមគោលការណ៍ច្បាប់ "អាជ្ញាអស់ជំនុំ (*Res Judicata*)" នៅពេលដែលចំណុចវិវាទដដែលមួយត្រូវបាននាំមកដោយភាគីវិវាទដដែលមកកាន់អង្គជំនុំជំរះមួយ ហើយអង្គជំនុំជំរះនោះបានចេញសេចក្តីសម្រេចលើចំណុចវិវាទនោះរួចមកហើយ អង្គជំនុំជំរះមានឆន្ទានុសិទ្ធិក្នុងការមិនលើកយកចំណុចវិវាទដដែលនោះមកពិចារណា និងសម្រេចម្តងទៀតបាន លើកលែងតែមានបទប្បញ្ញត្តិច្បាប់ជាធរមានចែងផ្ទុយពីនេះ។

នៅក្នុងដំណើរការនីតិវិធីអាជ្ញាកណ្តាលមិនមានបទប្បញ្ញត្តិច្បាប់ណាមួយ ចែងអំពីបញ្ហានេះឡើយ។ ដូចនេះជាទូទៅ ដោយយោងលើគោលការណ៍ច្បាប់ "អាជ្ញាអស់ជំនុំ (*Res Judicata*)" ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានឆន្ទានុសិទ្ធិក្នុងការពិចារណាថា តើត្រូវលើកយកចំណុចវិវាទដដែលរវាងភាគីវិវាទដដែល មកសម្រេចសារជាថ្មីឡើងវិញដែរឬទេ។ (សូមមើលសេចក្តីបង្គាប់*លេខ ៤៥/០៧-វិល ស៊ិន ហេតុផលចំណុចវិវាទទី២, លេខ ១៤/០៨-ហ្វ៊ីក ស៊ូ ហេតុផលចំណុចវិវាទទី១, លេខ២៦៤/០៩-ស៊ុីណូមេក ២ និងលេខ ៩៥/០៩-តាកហ្វាត ហេតុផលចំណុចវិវាទទី៣*)។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការសម្រេចលើចំណុចវិវាទនេះម្តងទៀតដែរ ឬទេ?

ដោយផ្អែកលើគោលការណ៍ "អាជ្ញាអស់ជំនុំ (*Res Judicata* )" ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ៤២/០៧-សៅថន៍បេ ហេតុផលនៃសម្រេចចំណុចវិវាទទី១ យល់ឃើញថា ចំណុចវិវាទមួយនឹងត្រូវបានបដិសេធពិចារណា ប្រសិនបើចំណុចវិវាទនេះបំពេញលក្ខខណ្ឌចំនួន៣ ដូចខាងក្រោម ៖

(១) ភាគីវិវាទធ្លាប់ចូលរួមលើចំណុចវិវាទនេះពីមុនមក

(២) ចំណុចវិវាទដែលធ្លាប់នាំមកក្រុមប្រឹក្សាអាជ្ញាកណ្តាល និង

(៣) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចលើអង្គសេចក្តីចប់សព្វគ្រប់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងដដែលបានលើកឡើងបន្ថែមទៀតថា គោលបំណងនៃការបដិសេធពិចារណាលើចំណុចទាមទារដដែលសារជាថ្មី គឺដើម្បីជៀសវាងនូវលទ្ធផលផ្ទុយគ្នាចំពោះដំណោះស្រាយវិវាទដដែល និងដើម្បីធានាថា ការដោះស្រាយវិវាទត្រូវបានបញ្ចប់ ដោយមានសេចក្តីសម្រេចមួយជាចុងក្រោយ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំនេះ ក៏ឯកភាពលើការបកស្រាយខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ ល័ក្ខខ័ណ្ឌទី១ត្រូវបានបំពេញពីព្រោះថា នៅក្នុងសំណុំរឿងលេខ ១៦២/១១ សហជីពមិត្តភាពកម្មករ គឺជាដើមបណ្ដឹងចំពោះក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី១។ ដូចនេះ ភាគីវិវាទគឺជាភាគីវិវាទតែមួយ។

ល័ក្ខខ័ណ្ឌទី២ ក៏ត្រូវបានបំពេញ ដោយហេតុថា នៅក្នុងសំណុំរឿងលេខ ១៦២/១១ សហជីពមិត្តភាពកម្មករ បានធ្វើការទាមទារលើចំណុចវិវាទដូចគ្នានេះ ចំពោះក្រុមហ៊ុន ខេមបូ ហ៊ែនសាំ អិលធីឌី ១ រួចមកហើយ។ ដូចនេះ ចំណុចវិវាទ ជាចំណុចវិវាទតែមួយ។

រីឯល័ក្ខខ័ណ្ឌទី៣ មិនត្រូវបានបំពេញទេ ដោយហេតុថា នៅក្នុងសំណុំរឿងលេខ ១៦២/១១ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនបានធ្វើការពិចារណា និងសម្រេចទៅលើអង្គសេចក្ដីឡើយ គឺក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានបដិសេធពិចារណាការទាមទារ។ ដូចនេះ នៅក្នុងសំណុំរឿងលេខ ១៦២/១១ អង្គសេចក្ដីមិនទាន់បានពិចារណា និងសម្រេចចប់សព្វគ្រប់នៅឡើយទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា គោលការណ៍ច្បាប់នៃអាជ្ញាអស់ជំនុំ មិនអាចអនុវត្តនៅក្នុងសំណុំរឿងនេះទេ ដែលមានន័យថា ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានយុត្តាធិការសម្រេចលើចំណុចវិវាទនេះម្ដងទៀត។

នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងធ្វើការពិចារណាថា តើនិយោជកត្រូវទទួលយកលោក វ៉ាន់ រីន លោក យី ដាវី និងលោក យី ដារ៉ុជ ឱ្យចូលធ្វើការងារវិញដែរ ឬទេ?

មាត្រា២៩៣នៃច្បាប់ស្ដីពីការងារចែងថា "*រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួន អាចធ្វើបានលុះត្រាណាតែមានការយល់ព្រមពីអធិការការងារ។ វិធានការការពារទាំងឡាយដូចគ្នានេះ ត្រូវអនុវត្តចំពោះអតីតប្រតិភូបុគ្គលិក ក្រោយពេលបញ្ចប់អាណត្តិរបស់ខ្លួនបីខែ និងក្នុងរយៈពេលបីខែចំពោះអតីតបេក្ខជនមិនជាប់ឆ្នោតក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោត។ រាល់គំរោងផ្លាស់ប្ដូរ ឬផ្ទេរការងាររបស់ប្រតិភូដែលនាំឱ្យមានការបាត់បង់តំណែងក្នុងអាណត្តិក៏ត្រូវដាក់ឱ្យស្ថិតក្រោមនីតិវិធីនេះដែរ។*

*អធិការការងារ ដែលបានទទួលពាក្យបណ្ដឹងសុំបញ្ឈប់កម្មករនិយោជិត ដូចមានចែងក្នុងមាត្រានេះ ត្រូវផ្ដល់សេចក្ដីសំរេចរបស់ខ្លួនដល់និយោជក ដល់កម្មករនិយោជិត ដែលត្រូវបញ្ឈប់ ក៏ដូចជាដល់អង្គការសហជីព ដែលគ្រប់គ្រងកម្មករនិយោជិតនោះ ក្នុងរយៈពេលមួយខែយ៉ាងយូរក្រោយទទួលពាក្យបណ្ដឹង។*

*បន្ទាប់ពីបានទទួលសេចក្ដីសំរេចនោះ និយោជក កម្មករនិយោជិត ដែលត្រូវបញ្ឈប់ ឬអង្គការសហជីពរបស់កម្មករនិយោជិតនោះមានរយៈពេលពីរខែ ដើម្បីធ្វើឧបាស្រ័យទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារអាចបដិសេធចោល ឬកែសំរួលសេចក្ដីសំរេចរបស់អធិការការងារ។*

*បើគ្មានការជូនដំណឹងអំពីសេចក្ដីសំរេចរបស់អធិការការងារក្នុងរយៈពេលដែលបានកំណត់ឱ្យទេ ឬបើគ្មានការជូនដំណឹងអំពីសេចក្ដីសំរេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារក្នុងរយៈពេលពីរខែ បន្ទាប់ពីបានទទួលឧបាស្រ័យតាមឋានានុក្រម នោះពាក្យបណ្ដឹងនិងឧបាស្រ័យនោះត្រូវចាត់ទុកថា បានបដិសេធចោល*"។

កថាខ័ណ្ឌទី២ នៃប្រការ ៤ នៃប្រកាសលេខ ៣០៥ សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ កំណត់ថា

THE ARBITRATION COUNCIL

*"...ការការពារនេះ ត្រូវបានផ្តល់ឱ្យអ្នកដឹកនាំសហជីព ០៣ នាក់ ក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៨២ និង ២៨៣ នៃច្បាប់ស្តីពីការងារ ។..."*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២៩៣ និងកថាខណ្ឌទី២ នៃប្រការ ៤ នៃប្រកាសលេខ ៣០៥ ផ្តល់ការការងារពារពិសេសដល់ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព ០៣ នាក់ ពីការបញ្ឈប់ពីការងារ ដោយតម្រូវឱ្យមានការទទួលយល់ព្រមពីអធិការការងារជាមុន ។ នីតិវិធីនៃការការពារពិសេសនេះ គឺតម្រូវឱ្យនិយោជកដាក់ពាក្យបណ្តឹងសុំបញ្ឈប់ទៅអធិការការងារ ហើយអធិការការងារត្រូវផ្តល់សេចក្តីសម្រេចក្នុងរយៈពេលកំណត់មួយខែ ក្រោយពីទទួលបានពាក្យបណ្តឹងសុំបញ្ឈប់ ។ ការអវត្តមាននៃការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អធិការការងារក្នុងរយៈពេលមួយខែ ត្រូវបានចាត់ថា អធិការការងារបានសម្រេចបដិសេធចោលពាក្យបណ្តឹងសុំបញ្ឈប់ ។

លើសពីនេះ មាត្រា ២៩៥ នៃច្បាប់ស្តីពីការងារ ចែងថា *"ករណីមានកំហុសធ្ងន់ នាយកសហគ្រាសអាចចេញសេចក្តីសំរេចបញ្ឈរជើងសាមីខ្លួនភ្លាមៗបាន ក្នុងការរងចាំសេចក្តីសំរេចរបស់អធិការការងារ ។ ក្នុងករណីដែលអធិការការងារមិនយល់ព្រមឱ្យបញ្ឈប់ការងាររបស់សាមីខ្លួន ការបញ្ឈរជើងនេះត្រូវទុកជាមោឃ ហើយផលនៃការបញ្ឈរជើង នេះក៏ត្រូវលុបចោលដោយពេញច្បាប់ដែរ"* ។

តាមរយៈអង្គហេតុ ចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ និយោជកបានព្យួរការងារលោក វ៉ាន់ វីន ជាប្រធានសហជីពមិត្តភាពកម្មករ, លោក យី ដាវី ជាអនុប្រធានសហជីពមិត្តភាពកម្មករ និងលោក យី ដាវុធ ជាប្រធានសហជីពពលកម្មកម្ពុជា ដោយហេតុថា អ្នកទាំង៣រូបបានប្រព្រឹត្តកំហុសធ្ងន់ ។ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ និយោជកបានដាក់ពាក្យបណ្តឹងសុំបញ្ឈប់អ្នកទាំង៣រូបទៅនាយកដ្ឋានវិវាទការងារ ។ នាយកដ្ឋានវិវាទការងារធ្វើការឆ្លើយតបទៅលើពាក្យបណ្តឹងសុំបញ្ឈប់របស់និយោជក នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ។ ការឆ្លើយតបរបស់នាយកដ្ឋានវិវាទការងារ ធ្វើឡើងនៅក្រោយរយៈពេលកំណត់មួយខែ ក្រោយពីថ្ងៃទទួលបានពាក្យបណ្តឹងសុំបញ្ឈប់ ។ ដូចនេះ ផ្អែកលើមាត្រា ២៩៣ និងមាត្រា ២៩៥ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យបណ្តឹងសុំបញ្ឈប់លោក វ៉ាន់ វីន លោក យី ដាវី និងលោក យី ដាវុធ ពីការងាររបស់និយោជក ត្រូវបានបដិសេធចោល ដែលមានន័យថា ការព្យួរការងាររបស់អ្នកទាំង៣រូប ត្រូវចាត់ទុកជាមោឃៈ ។

ដូចនេះ ដោយអនុលោមតាមនីតិវិធីច្បាប់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបង្គាប់ឱ្យនិយោជកទទួលយកលោក វ៉ាន់ វីន លោក យី ដាវី និងលោក យី ដាវុធ ឱ្យចូលធ្វើការនៅកន្លែងដើមវិញ និងសងប្រាក់រំលឹកចាប់ពីថ្ងៃព្យួរការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ ។

ប៉ុន្តែ ដោយផ្អែកលើដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញលេខ ១៦ "ជ" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលមានសេចក្តីសម្រេចត្រង់ចំណុចទី១ កំណត់ថា *"បង្គាប់ឱ្យកម្មករនិយោជិត ដែលកំពុងចូលរួមធ្វើកូដកម្មនៅមុខរោងចក្រ ខេមបូ ហ៊ែនសាំ អិលធីឌី១... លើកលែងតែឈ្មោះ ដែលត្រូវបានក្រុមហ៊ុនព្យួរការងារតាមនីតិវិធីច្បាប់ស្តីពីការងារ រងចាំរហូតដល់រឿងអង្គសេចក្តីត្រូវបានតុលាការដោះស្រាយចប់ជាស្ថាពរ"* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សេចក្តីបង្គាប់អាជ្ញាកណ្តាលនៅក្នុងចំណុចវិវាទនេះ មិនមានអានុភាពអនុវត្តភ្លាមបានទេ ។ សេចក្តីបង្គាប់អាជ្ញាកណ្តាលនៅក្នុងចំណុចវិវាទនេះ នឹងត្រូវអនុវត្តភ្លាមនៅពេលដែល

ARBITRATION COUNCIL

អង្គសេចក្តីទាក់ទងនឹងសំណុំរឿង លោក វ៉ាន់ វីន លោក យី ដាវី និងលោក យី ដារ៉ុច ត្រូវបានតុលាការដោះស្រាយចប់ជាស្ថាពរ ។

ចំណុចវិវាទទី២៖ កម្មករនិយោជិតទាមទារឱ្យនិយោជកដកពាក្យបណ្តឹងអាជ្ញាចោទប្រកាន់លោក វ៉ាន់ វីន និងពាក្យបណ្តឹងរដ្ឋប្បវេណីទាមទារសំណងចំនួន ១៦៣០០ ដុល្លារអាមេរិក ពីលោក យី ដាវី និងលោក យី ដារ៉ុច ពីសាលាដំបូងរាជធានីភ្នំពេញ

ដោយអនុលោមទៅតាមជំពូក១២ ផ្នែកទី២ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការក្នុងការសម្រេចតែលើវិវាទការងាររួមប៉ុណ្ណោះ ។ (សូមមើលសេចក្តីបង្គាប់សេចក្តីបង្គាប់អាជ្ញាកណ្តាល *លេខ ៩៤/០៤-អេ អាយ អេ ហេតុផលចំណុចវិវាទទី៦, លេខ ៨១/០៦-ហុង អ៊ីហេតុផលចំណុចវិវាទទី១ និងលេខ ៨៣/០៦-ហេតុផលចំណុចវិវាទទី១*) ។

មាត្រា៣០២ នៃច្បាប់ការងារចែងថា ៖ *"វិវាទការងាររួមគឺជាវិវាទដែលកើតឡើង... អំពីរឿងល័ក្ខខ័ណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈ ក្នុងសហគ្រាស ... រវាងនិយោជក និងកម្មករនិយោជិត..."* ។

ផ្អែកលើមាត្រា ៣០២ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មវត្ថុចម្បងនៃវិវាទការងាររួមដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការសម្រេច គឺជាវិវាទការងាររួម ដែលទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈក្នុងសហគ្រាសជាដើម ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារនៅក្នុងចំណុចនេះ ដែលឱ្យនិយោជកដកពាក្យបណ្តឹងអាជ្ញាចោទប្រកាន់លោក វ៉ាន់ វីន និងពាក្យបណ្តឹងរដ្ឋប្បវេណីទាមទារសំណងចំនួន ១៦៣០០ ដុល្លារអាមេរិក ពីលោក យី ដាវី និងលោក យី ដារ៉ុច ពីសាលាដំបូងរាជធានីភ្នំពេញ មិនមានកម្មវត្ថុវិវាទ ដូចដែលកំណត់នៅក្នុងមាត្រា ៣០២ ខាងលើឡើយ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារឱ្យនិយោជកដកពាក្យបណ្តឹងចំពោះកម្មករនិយោជិតណាម្នាក់នៅឯតុលាការអាជ្ញាធរ មិនស្ថិតក្នុងដែនយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកដកពាក្យបណ្តឹងអាជ្ញាចោទប្រកាន់លោក វ៉ាន់ វីន និងពាក្យបណ្តឹងរដ្ឋប្បវេណីទាមទារសំណងចំនួន ១៦៣០០ ដុល្លារអាមេរិក ពីលោក យី ដាវី និងលោក យី ដារ៉ុច ពីសាលាដំបូងរាជធានីភ្នំពេញ ។

ចំណុចវិវាទទី៣ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ជំនាញជូនកម្មករចេះម៉ាស៊ីនមួយចំនួន៣ដុល្លារអាមេរិក ចេះម៉ាស៊ីនពីរចំនួន ៦ ដុល្លារដុល្លារអាមេរិក និងចេះម៉ាស៊ីន៣ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ជំនាញដល់កម្មករនិយោជិត ចេះម៉ាស៊ីនដូចដែលបានទាមទារដែរ ឬទេ?

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានបទប្បញ្ញត្តិច្បាប់ស្តីពីការងារណាមួយ ឬអនុសញ្ញារួម ឬកិច្ចព្រមព្រៀងណាមួយរវាងនិយោជក និងភាគីកម្មករនិយោជិត ដែលចែងអំពីការផ្តល់ប្រាក់ជំនាញដល់កម្មករនិយោជិតដែលមានជំនាញម៉ាស៊ីននេះទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារនេះ គឺជាការទាមទារដែលលើសពីច្បាប់ផ្តល់ឱ្យ ។ ដូចនេះ ចំណុចវិវាទនេះ គឺជាចំណុចវិវាទអំពីផលប្រយោជន៍ ។

ជាទូទៅចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាលើភាពជាតំណាងបំផុតរបស់សហជីព ដែលជាភាគីវិវាទ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពផ្តល់សិទ្ធិតាមផ្លូវច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ក្នុងការនាំសំណុំរឿងវិវាទអំពីប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។

មាត្រា៤៣ នៃប្រកាសលេខ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា "*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលដោះស្រាយវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍ នឹងមកជំនួសអនុសញ្ញារួមសម្រាប់រយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃដែលសេចក្តីបង្គាប់នោះចូលជាស្ថាពរ លើកលែងតែភាគីចរចាបង្កើតអនុសញ្ញារួមមួយ ដើម្បីជំនួសសេចក្តីបង្គាប់នេះ*" ។

យោងតាមខ្លឹមសារនៃមាត្រា៤៣ ខាងលើ សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីផលប្រយោជន៍នឹងក្លាយជាអនុសញ្ញារួមដែលអនុវត្តទៅលើកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ហើយធ្វើឱ្យកម្មករនិយោជិតដទៃទៀត ដែលមិនមែនជាសមាជិកសហជីពនេះបាត់បង់សិទ្ធិក្នុងការធ្វើកូដកម្ម ដើម្បីទាមទារលើវិវាទដែលទាក់ទងនឹងផលប្រយោជន៍នាពេលអនាគត ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការដោះស្រាយវិវាទអំពីផលប្រយោជន៍បាន លុះត្រាតែសហជីពដែលទាមទារនាំយកវិវាទនោះមក ជាសហជីពដែលមានភាពជាតំណាងនៅក្នុងសហគ្រាស ឬសហជីពច្រើនរួមគ្នាទៅមានចំនួនសមាជិកលើសពីពាក់កណ្តាលនៃកម្មករនិយោជិតនៅក្នុងសហគ្រាស (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ៨១/០៤-អេវើហ្គ្រីន ចំណុចវិវាទទី៤ និងលេខ ៩៨/០៤-ហ្គ្រេតយូនៀន ចំណុចវិវាទទី៣*) ។

នៅក្នុងសំណុំរឿងលេខ ១៦៩/១១-ហ្វ័រធ្យូនធីវ ចំណុចវិវាទទី៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាវិវាទអំពីផលប្រយោជន៍ ដោយសារសហជីពដែលនាំវិវាទការងារនោះមក ជាសហជីពដែលមិនមានភាពតំណាងបំផុតនៅក្នុងរោងចក្រ (*សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ០២/១១-ពូយៀន ហេតុផលចំណុចវិវាទទី២ និងលេខ ៦៦/១១-អ៊ិនហានស៊ុង ហេតុផលចំណុចវិវាទទី១*) ។

នៅក្នុងសំណុំរឿងនេះ សហជីពមិត្តភាពកម្មករមិនមានភាពជាតំណាងបំផុតនៅក្នុងក្រុមហ៊ុនទេ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពនេះពុំមានមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ក្នុងការធ្វើជាតំណាងឱ្យកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទ ដែលទាក់ទងនឹងផលប្រយោជន៍របស់កម្មករនិយោជិតនៅក្នុងក្រុមហ៊ុនទេ ។

THE ARBITRATION COUNCIL

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ជំនាញជូនកម្មករចេះម៉ាស៊ីនមួយ ចំនួន៣ដុល្លារអាមេរិក ចេះម៉ាស៊ីនពីរចំនួន ៦ដុល្លារអាមេរិក និង ចេះម៉ាស៊ីន ៣ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ ។

**ចំណុចវិវាទទី៤៖ កម្មករនិយោជិតទាមទារឱ្យនិយោជកបន្ថែមប្រាក់ឈ្នួលចំនួន ៥ដុល្លារអាមេរិកឱ្យកម្មករនិយោជិតដែលមានអតីតភាពការងារលើសពី ២ឆ្នាំ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលបន្ថែមចំនួន ៥ ដុល្លារអាមេរិក ឱ្យកម្មករនិយោជិតដែលមានអតីតភាពការងារលើសពី ២ឆ្នាំដែរ ឬទេ?

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានបទប្បញ្ញត្តិច្បាប់ស្តីពីការងារណាមួយ ឬអនុសញ្ញារួម ឬកិច្ចព្រមព្រៀងណាមួយរវាងនិយោជក និងកម្មករនិយោជិត ដែលចែងអំពីកាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់ប្រាក់ឈ្នួលបន្ថែមឱ្យកម្មករនិយោជិត ដែលមានអតីតភាពការងារលើសពី២ឆ្នាំឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទារនេះ គឺជាការទាមទារដែលលើសពីច្បាប់ផ្តល់ឱ្យ ។ ដូចនេះ ចំណុចវិវាទនេះ គឺជាចំណុចវិវាទអំពីផលប្រយោជន៍ ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលបន្ថែមឱ្យកម្មករនិយោជិត ដែលមានអតីតភាពការងារលើសពី២ឆ្នាំ ចំនួន៥ដុល្លារអាមេរិក ។ (សូមមើលហេតុផលសេចក្តីសម្រេចនៅក្នុងចំណុចវិវាទទី៣ខាងលើ) ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ ៖**

សេចក្តីបង្គាប់អាជ្ញាកណ្តាលនៅក្នុងចំណុចវិវាទនេះ នឹងត្រូវអនុវត្តភ្លាមនៅពេលដែលអង្គសេចក្តីទាក់ទងនឹងសំណុំរឿង លោក វ៉ាន់ វីន លោក យី ដាវី និងលោក យី ដារ៉ុច ត្រូវបានតុលាការដោះស្រាយចប់ជាស្ថាពរ ។

**ចំណុចវិវាទទី២ ៖**

បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកដកពាក្យបណ្តឹងអាជ្ញាចោទប្រកាន់លោក វ៉ាន់ វីន និងពាក្យបណ្តឹងរដ្ឋប្បវេណីទាមទារសំណងចំនួន ១៦៣០០ដុល្លារអាមេរិក ពីលោក យី ដាវី និងលោក យី ដារ៉ុច ពីសាលាដំបូងរាជធានីភ្នំពេញ ។

**ចំណុចវិវាទទី៣ ៖**

បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ជំនាញជូនកម្មករចេះម៉ាស៊ីនមួយចំនួន៣ដុល្លារអាមេរិក ចេះម៉ាស៊ីនពីរចំនួន៦ដុល្លារអាមេរិក និងចេះម៉ាស៊ីន៣ចំនួន១០ដុល្លារអាមេរិកក្នុងមួយខែ ។

ARBITRATION COUNCIL

ចំណុចវិវាទទី៤ ៖

បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលបន្ថែមឱ្យកម្មករនិយោជិត ដែលមានអតីតភាពការងារលើសពី២ឆ្នាំ ចំនួន ៥ ដុល្លារអាមេរិក ។

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់ជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង បន្ទាប់ពីសេចក្តីបង្គាប់នេះចេញទៅ ដោយសារភាគីទាំងពីរបានយល់ព្រមជ្រើសរើសយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ច នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១២ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា: ---------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា: ---------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **នុន សារ៉ាយ**

ហត្ថលេខា: ---------------------------------------

THE ARBITRATION COUNCIL